# ប្រាថ្នាចុងក្រោយ

ចិត្តដឹងច្បាស់ហើយអូនអើយត្រូវឃ្លាត
ចង់លើកហត្ថាជូតទឹកភ្នែកមុំ
ទ្រូងសែនចង្អៀតពេលឃើញអូនយំ
អនិច្ចាកាយខ្ញុំពុំតាមប្រាថ្នា។

ចង់ហៅឈ្មោះអូនមួយគ្រាចុងក្រោយ
ចង់ពោលប្រាប់អូនស្ងួនកុំទុក្ខា
ចង់ញញឹមឱ្យអូនស្ងប់ចិន្តា
ធ្វើម្តេចវាសនាចារជួបត្រឹមហ្នឹង។

ចង់លោមឆោមឆាយកាយធ្វើមិនបាន
ធ្វើម្តេចនិមលអូនយល់អូនដឹង
ទុព្វលគ្រប់ប្រាណបានត្រឹមសម្លឹង
អូនអើយកុំខឹងនឹងភ័ព្វវាសនា។



កុំសោកាថ្វីពិសីវរមិត្ត
ធម្មតាជីវិតតែងអនត្តា
សូមឱ្យស្នេហ៍យើងជាអនុស្សារ
មួយគ្រាថ្លៃថ្លាក្នុងដួងចិត្តអូន។

ប៊ុនចាន់ ជ័យរាជ អភ័យសង្គ្រាម
សុក្រសិរី